**SAN JOAQUIN COUNTY BEHAVIORAL HEALTH SERVICES**
1212 NORTH CALIFORNIA STREET ♦ STOCKTON, CA 95202
Tel: (209) 468-8700 ♦ Fax: (209) 468-2399

**Mental Health Services ♦ Substance Abuse Services ♦ Conservator Services ♦ Mental Health Pharmacy**

DEPARTMENT OF
HEALTH CARE SERVICES

ថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨

# សេចក្តីស្នើសុំកែប្រែថវិកានាឆ្នាំបច្ចុប្បន្នសំរាប់គំរោងគោលការណ៍នៃការព្យាបាលវិបត្តិផ្នែកផ្លូវចិត្តកម្លុងពេលបីឆ្នាំ (២០០៥-២០០៨)

## ការឲ្យសេចក្តីយល់ព្រម :

មានឲ្យសេចក្តីយល់ព្រមថា Behavioral Health Services បានសុំការអនុម័តអំពី State Department of Mental Health ដើម្បីកែប្រែថវិកានៅឆ្នាំទីបីនៃ Mental Health Services Act (MHSA) គំរោងបីឆ្នាំដោយបង្កើនចំនួន $1,902,760. ប្រាក់នេះ មិនទាន់មានគំរោងនិងចំណាយនាបច្ចុប្បន្ន ហើយនឹងត្រូវប្រើដើម្បីបង្កើនការព្យាបាល និងកម្មវិធីផ្សេងៗ

## ហេតុនៃការឲ្យសេចក្តីយល់ព្រម :

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០០៦ State Department of Mental Health (DMH) បានអនុម័តគំរោងការណ៍បីឆ្នាំឲ្យ MHSA Community Services and Supports Component នៅដំបន់ San Joaquin ។
នៅពេលនោះមាន $2,453,900 នៃចំនួនសារុប $5,589,700 នៃគំរោងវាយតម្លៃមើលសំរាប់ឆ្នាំ២០០៥-០៦ ដែលបានអនុម័តសំរាប់ការចំណាយ។ នៃប្រាក់ដែលនៅសល់ $3,135,800 គំរោងផ្តល់ប្រាក់មួយផងសំរាប់បច្ចេកវិទ្យាចំនួន $1,233,040 បានស្នើសុំ និងអនុម័តដោយ DMH នៅថ្ងៃទី៧ ខែកុម្ភះ ឆ្នាំ២០០៨។ $1,902,760 ជាប្រាក់សល់នៅ ហើយនឹងត្រូវប្រើដើម្បីបង្កើនការព្យាបាលដែលបានអនុម័តពីមុនសំរាប់កម្មវិធី Full Service Partnership សំរាប់ជនពេញវ័យ ហើយដើម្បីចាប់ផ្តើមកម្មវិធី Prudent Reserve.
ការឲ្យសេចក្តីយល់ព្រមដើម្បីសុំឲ្យ DMH អនុម័តបង្កើនការព្យាបាល និងកម្មវិធី បានពិនិត្យឡើងវិញដោយ Mental Health Board នៃដំបន់ San Joaquin នៅថ្ងៃទី២០ ខែកុម្ភះ ឆ្នាំ២០០៨ និងជាមួយ MHSA Stakeholder Steering Committee នៅថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៨។

## ការបះពាល់ថវិកា :

បើការផ្តល់ប្រាក់នេះមិនបានថែមបញ្ចូល រដ្ឋនឹងដូរគំនិត ហើយលៃប្រាក់នេះឲ្យទៅដំបន់ផ្សេងទៀត។

## សកម្មភាពបន្តរដែលត្រូវអនុវត្តន៍ :

សូមស្វាគមន៍នូវយោបល់ផ្សេងៗ ហើយសូមផ្ញើតាមអ៊ីមែលមក : mhsacomments@sjcbhs.org.
សូមផ្ញើយោបល់ផ្សេងៗតាមក្រដាសមក Becky Gould នៅ 1212 N. California St, Stockton, CA 95202. បន្ទាប់ពីការឆ្លើយតបការប្រកាសជាសាធារណៈក្នុងរវាង៣០ថ្ងៃបានផ្សាយចប់សព្វគ្រប់ លិខិតដាក់ពាក្យស្នើសុំកែប្រែថវិកា និងឯកសារជាប់ទាក់ទងគាំទ្រ នឹងត្រូវផ្ញើទៅ State Department of Mental Health ដើម្បីពិនិត្យសារឡើងវិញ ហើយនឹងអនុម័ត។

(Cambodian)